**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង

## ស្តីអំពី

# ការបែងចែកការទទួលខុសត្រូវ លើការគ្រប់គ្រង និងថែទាំ ជួសជុល ប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត

## រវាង

- មន្ទីរធនធានទឹក និងឧតុនិយម ខេត្តកំពង់ធំ

- សហគមន៍កសិករប្រើប្រាស់ទឹក ប្រព័ន្ធរាសាស្ត្រស្ទឹងជីនិត

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

យោងតាមៈ

- សារាចរណ៍ លេខ ០១ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១១ ខែមករា ឆ្នាំ១៩៩៩ ស្តីពី ការអនុវត្តន៍គោលនយោបាយនិរន្តរភាពនៃប្រព័ន្ធធារាសាស្ត្រ
- ប្រកាសលេខ ៣០៦ ប្រក.ធ.ទ.ឱ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០០០ របស់ក្រសួងធនធានទឹក និងឧតុនិយមស្តីពី ការប្រើប្រាស់ជាផ្លូវការនូវឯកសារជាមូលដ្ឋានដើម្បីបង្កើត និងអភិវឌ្ឍន៍ ស.ក.ប.ទ
- ប្រកាសលេខ ០៨៨ ប្រក.ធ.ទ.ឱ ចុះថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០០៦ របស់ក្រសួងធនធានទឹក និងឧតុនិយមស្តីពី ការប្រើប្រាស់ជាផ្លូវការនូវ លក្ខន្តិកៈសហគមន៍កសិករប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត (ស.ក.ប.ទ/ប្រ.ធ.ស.ជ)
- ដីការសាលាខេត្ត ១១៧ ចេញថ្ងៃទី ២៨ ខែវិច្ឆកា ឆ្នាំ២០០៧ ស្តីអំពីការបង្កើតគណៈកម្មាធិការទ្រទ្រង់អាងទឹកប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត

## កិច្ចព្រមព្រៀងអនុវត្តដោយ

មន្ទីរធនធានទឹក និងឧតុនិយម ខេត្តកំពង់ធំ តំណាងដោយ លោក ជាតិ ស៊ីវុត្ថា ប្រធានមន្ទីរ

## និង

សហគមន៍កសិករប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត តំណាងដោយ លោក អ៊ឹម អៀប ប្រធានគណៈកម្មា ធិការសហគមន៍

## ខ្លឹមសារនៃកិច្ចព្រមព្រៀងនេះមានដូចខាងក្រោមៈ

<u>ប្រការ ១ គោលបំណង</u>

- កិច្ចព្រមព្រៀងនេះ រៀបចំឡើងដើម្បីកំណត់ ការបែងចែកការទទួលខុសត្រូវលើការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត។
- កិច្ចព្រមព្រៀងនេះ មានចែងលំអិតអំពី ការទទួលខុសត្រូវរបស់ភាគីទាំងពីរខាងលើ ដើម្បីអោយកិច្ចដំណើរការ និងការថែទាំ-ជួសជុល លើប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត ប្រព្រឹត្តទៅបានរលូន និងមាននិរន្តរភាព។

<u>ប្រការ ២ ការទទួលខុសត្រូវរបស់សហគមន៍កសិករប្រើប្រាស់ទឹក</u>

### ២.១- ការទទួលខុសត្រូវលើ ការថែទាំ

សហគមន៍កសិករប្រើប្រាស់ទឹក ធានាធ្វើការថែទាំ-ជួសជុលលើប្រឡាយ និងសំណង់សិល្បការមួយចំនួន ដូចខាងក្រោម៖

- ការជួសជុលបន្ទាន់ ការថែទាំមុនរដូវកាលដាំដុះ ការថែទាំជាប្រចាំ លើប្រឡាយរង (ប្រភេទប្រឡាយទី២) រួមទាំងសំណង់ដែលនៅប្រឡាយរងទាំងនោះ (សំណង់ស្ទាក់ទឹក សំណង់ដោះទឹកចុងប្រឡាយរង សំណង់បង្ហៀរនៅពាក់កណ្តាលប្រឡាយរង សំណង់មុខទឹកចូលប្លុក ស្ពាន)។
- ការជួសជុលបន្ទាន់ ការថែទាំមុនរដូវកាលដាំដុះ ការថែទាំជាប្រចាំ លើសំណង់ស្ទាក់ទឹកក្នុងប្រឡាយដោះទឹកធំនិងស្ពាននៅតាមប្រឡាយដោះទឹកធំ។
- ការជួសជុលបន្ទាន់ ការថែទាំមុនរដូវកាលដាំដុះ ការថែទាំជាប្រចាំ លើប្រឡាយស្រោចស្រពប្លុក និងប្រឡាយដោះទឹកប្លុក និងសំណង់នៅលើប្រឡាយទាំងនោះ (សំណង់ស្ទាក់ទឹកចុងប្រឡាយដោះទឹកប្លុក សំណង់បង្ហៀរចុងប្រឡាយស្រោចស្រពប្លុក សំណង់ស្ទាក់ទឹកក្នុងប្រឡាយ)។
- ការជួសជុលបន្ទាន់ ការថែទាំមុនរដូវកាលដាំដុះ ការថែទាំជាប្រចាំ លើប្រព័ន្ធផ្លូវចេញចូលស្រែក្នុងប្លុក និងផ្លូវអែមប្រឡាយរង។

### ២.២- ការទទួលខុសត្រូវលើ កិច្ចដំណើរការស្រោចស្រព

សហគមន៍កសិករប្រើប្រាស់ទឹក ធានាធ្វើការងារគ្រប់គ្រង និងបែងចែកទឹកនៅក្នុងប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត ដោយទទួលខុសត្រូវលើការបើកឬបិទ ឬត្រួតពិនិត្យលើ សំណង់សិល្បការមួយចំនួនមាន ដូចខាងក្រោម៖

- ទ្វារទឹកប្រឡាយរង (ប្រភេទប្រឡាយទី២)
- សំណង់ស្ទាក់ទឹក្នុងប្រឡាយរង សំណង់ផ្លូម(មុខទឹកបញ្ចូលប្លុក)
  សំណង់ស្ទាក់ទឹកតាមប្រឡាយដោះទឹកធំ
- សំណង់ស្ទាក់ទឹកតាមប្រឡាយដោះទឹកប្លុក។ល។

<u>ប្រការ ៣ ការទទួលខុសត្រូវរបស់មន្ទីរធនធានទឹក និងឧតុនិយម</u>

### ៣.១- ការទទួលខុសត្រូវលើ ការថែទាំ

មន្ទីរធនធានទឹក និងឧតុនិយម ធានាធ្វើការថែទាំ-ជួសជុលលើប្រឡាយ និងសំណង់សិល្បការមួយចំនួន៖

- ការជួសជុលបន្ទាន់ ការថែទាំមុនរដូវកាលដាំដុះ ការថែទាំជាប្រចាំ លើអាងទឹក និងសំណង់សិល្បការមួយចំនួនស្ថិតនៅលើទំនប់អាង (សំណង់បង្ហៀរ សំណង់ទ្វារដោះទឹកអាង សំណង់ជណ្តើរត្រី ។ល។)
- ការជួសជុលបន្ទាន់ ការថែទាំមុនរដូវកាលដាំដុះ ការថែទាំជាប្រចាំ លើប្រឡាយមេ និងទ្វារទឹកប្រឡាយមេ
- ការជួសជុលបន្ទាន់ ការថែទាំមុនរដូវកាលដាំដុះ ការថែទាំជាប្រចាំ លើប្រឡាយដោះទឹកធំ
- ការជួសជុលបន្ទាន់ ការថែទាំមុនរដូវកាលដាំដុះ ការថែទាំជាប្រចាំ លើផ្លូវអែមប្រឡាយមេ
- ការជួសជុលបន្ទាន់ ការថែទាំមុនរដូវកាលដាំដុះ ការថែទាំជាប្រចាំ លើផ្លូវអែមប្រឡាយដោះទឹកធំ

ធ្វើការត្រួតពិនិត្យ និងវាយតំលៃលើស្ថានភាពប្រឡាយមេ ប្រឡាយដោះទឹកធំ ផ្លូវលំអមតាមប្រឡាយមេ ប្រឡាយដោះទឹកធំ និងសំណង់សិល្បការមួយចំនួនដែលនៅលើប្រឡាយទាំងនោះ។

ករណីមានគ្រោះធម្មជាតិ ធ្វើអោយខូចខាតប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត មន្ទីរធនធានទឹក និងឧតុនិយម នឹងស្វែងរកថវិកា ឬសហការជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីជួសជុល ឬសាងសង់ឡើងវិញនូវប្រព័ន្ធប្រឡាយ ឬសំណង់ណាដែលខូចខាត។

### ៣.២- ការទទួលខុសត្រូវលើ កិច្ចដំណើរការស្រោចស្រព

មន្ទីរធនធានទឹក និងឧតុនិយម ជានាទទួលធ្វើការងារគ្រប់គ្រង និងបែងចែកទឹកនៅក្នុងប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត ដោយទទួលខុសត្រូវលើការបើកឬបិទ ឬត្រួតពិនិត្យលើ សំណង់សិល្បការមួយចំនួនមានដូចខាងក្រោម៖

- ទ្វារទឹកប្រឡាយមេ
- សំណង់ជណ្តើរត្រី
- សំណង់បង្ហៀរអាងទឹក
- ទ្វារដោះទឹកពីអាង

ចូលរួមប្រជុំប្រចាំសប្តាហ៍ស្តីអំពីការកំណត់កំរិតកំពស់ទឹក ជាមួយគណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹក នៅក្នុងកំឡុងពេលដំណើរការបែងចែកទឹកស្រោចស្រព។

### ៣.៣-ការប្រឹក្សាយោបល់ និងអ្នកតំណាង

- មន្ទីរធនធានទឹក និងឧតុនិយម ធ្វើការសំរបសំរួល រាល់ការទំនាក់ទំនងជាមួយស្ថាប័នសាធារណៈផ្សេងៗ ដែលពាក់ព័ន្ធជាមួយការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត។
- មន្ទីរធនធានទឹក និងឧតុនិយម ចូលរួមផ្តល់យោបល់ អោយសហគមន៍កសិករប្រើប្រាស់ទឹក តាមការស្នើសុំរបស់គណៈកម្មាធិការសហគមន៍ពាក់ព័ន្ធជាមួយ ការធ្វើផែនការបែងចែកទឹកស្រោចស្រព ការរៀបចំគំរោងថវិកា និងការគណនាតំលៃប្រាក់សេវាកម្ម ។

<u>ប្រការ ៤ សិទ្ធិគ្រប់គ្រង ចាត់ចែងលើអចលនទ្រព្យ នៃប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត</u>

- ប្រព័ន្ធប្រឡាយ និងសំណង់សិល្បការ នៅក្នុងប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត ជាអចលនទ្រព្យរបស់ក្រសួងធនធានទឹក និងឧតុនិយម។
- សហគមន៍កសិករប្រើប្រាស់ទឹក មានសិទ្ធិគ្រប់គ្រងចាត់ចែងលើ កិច្ចដំណើរការ ប្រព័ន្ធប្រឡាយរង និងសំភារៈទាំងឡាយទទួលបានពីគំរោងស្ទឹងជីនិត សំរាប់ប្រើប្រាស់លើកិច្ចដំណើរការនេះ។

<u>ប្រការ ៥ ប្រភពថវិកា សំរាប់កិច្ចដំណើរការ និងជួសជុលថែទាំ</u>

ប្រភពថវិកា សំរាប់អនុវត្តកិច្ចដំណើរការ និងជួសជុលថែទាំ ប្រព័ន្ធប្រឡាយ និងសំណង់សិល្បការក្នុងប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត៖

- ថវិការបស់ក្រសួងធនធានទឹក និងឧតុនិយម
- ថវិការបស់មន្ទីរធនធានទឹក និងឧតុនិយម
- ប្រាក់សេវាកម្មប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត
- មូលនិធិឃុំ-សង្កាត់

- មូលនិធិស្រុក ខណ្ឌ
- ជំនួយពីអង្គការជាតិ និងអន្តរជាតិ
- ជំនួយពីសប្បុរសជន
- ចំណូលផ្សេងៗ

មន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ធំ និងសហគមន៍កសិករប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត សហការគ្នា ខិតខំរកថវិកា ពីប្រភពខាងលើ ដើម្បីបំពេញការងារដែលស្ថិតនៅក្រោមការទទួលខុសរបស់ខ្លួនអោយអស់ពីលទ្ធភាព។

## ប្រការ ៦ ការត្រួតពិនិត្យ និងវាយតំលៃ

- និតិវិធីសំរាប់ត្រួតពិនិត្យ និងវាយតំលៃលើកិច្ចព្រមព្រៀងនេះ នឹងត្រូវបានរៀបចំឡើង និងអនុម័តនៅក្នុងគណៈកម្មាធិការទ្រទ្រង់អាងទឹកស្ទឹងជីនិត។
- និតិវិធីនេះ និងត្រូវដាក់ជូនក្រសួងធនធានទឹក និងឧតុនិយមពិនិត្យ និងអនុម័តបន្ទាប់ពីភាគីទាំងបីឯកភាពគ្នា។

## ប្រការ ៧ ការដោះស្រាយវិវាទ

គណៈកម្មាធិការទ្រទ្រង់អាងទឹកស្ទឹងជីនិត ជាវេទិការសំរាប់ពិភាក្សា ប្រឹក្សាយោបល់ សំរាប់ដោះស្រាយបញ្ហា ឬវិវាទ ដែលអាចកើតមានឡើង ក្នុងកំឡុងពេលអនុវត្តកិច្ចព្រមព្រៀង។

## ប្រការ ៨ សុពលភាពនៃកិច្ចព្រមព្រៀង

១. សុពលភាព នៃកិច្ចព្រមព្រៀងនេះ សំរាប់រយៈពេលអន្តរកាល ៣ ឆ្នាំ
២. ភាគីទាំងអស់ អាចស្នើរអោយរៀបចំឯកសារឧបសម្ព័ន្ធ នឹងដាក់អនុម័ត ដើម្បីធ្វើអោយខ្លឹមសារ ក្នុងកិច្ចព្រមព្រៀងនេះ សមស្របតាមស្ថានភាពជាក់ស្តែង។
៣. ការប្រកាសបដិសេធ នឹងខ្លឹមសារកិច្ចព្រមព្រៀង ដោយភាគីតែមួយ ក្នុងចំណោមភាគីទាំងអស់ នឹងមិនមានសុពលភាពទេ។
៤. នៅពេលកិច្ចព្រមព្រៀងនេះផុត សុពលភាព ភាគីទាំងពី នឹងរៀបចំ អនុសារណៈយោគយល់ ស្តីអំពីការបែងចែកការទទួលខុសត្រូវលើការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ។

| | |
|---|---|
| ប្រធាន | ប្រធានគណៈកម្មាធិការ |
| មន្ទីរធនធានទឹក និងឧតុនិយម ខេត្តកំពង់ធំ | សហគមន៍កសិករប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត |
| ជាតិ_ស៊ីទុត្ថា | |